## Breaking appointments



១ សម្ផស្ស៖ អាឡូ សុភ័ក្រ ទំនេរអត់? និយាយតិចបានអេ៉?

សុភ័ក្រ៖ បានតាស ម៉េចដែរ?

សម្ផស្ស៖ ថាអញ្ចេក ង៉ៃអាទិត្យហ្នឹងថាទៅញ៉ាំអីជាមួយគ្នាអ៊ំ លើកទៅថ្ងៃអាទិត្យក្រោយវិញបានអេ៉ សុភ័ក្រ? ខ្ញុំត្រូវទៅសៀមរាបថ្ងៃស្អែករហូតដល់អាទិត្យក្រោយថ្ងៃចន្ទ បានបានមកវិញ។

សុភ័ក្រ៖ ថ្ងៃអាទិត្យក្រោយ ខ្ញុំរវល់ហ្នឹង សម្ផស្ស។ ថ្ងៃសៅរ៍បានអេ៉?

សម្ផស្ស៖ ថ្ងៃសៅរ៍ក៏បាន។ សុំទោសណាសុភ័ក្រ។

សុភ័ក្រ៖ អត់អីទេ។ អីចឹង សម្រេចថាជួបគ្នាថ្ងៃសៅរ៍វិញ។

២ បងប្រុស៖ ពិសី ថាង៉ៃអាទិត្យហ្នឹងទៅជួយមើលកុំព្យូទ័រឲ្យពួកម៉ាកអូនឯងអ៊ំ ដូរង៉ៃវិញបានអេ៉? បងរវល់តិចអាទិត្យហ្នឹង។

ប្អូនស្រី៖ ទាល់តែខ្ញុំសួរពួកម៉ាកខ្ញុំសិន។ ចុះបងទំនេរង៉ៃណា?

បងប្រុស៖ បើមិននេះ ទៅង៉ៃស្អែកម៉ងទៅ ម៉េចដែរ?

ប្អូនស្រី៖ ង៉ៃស្អែកខ្ញុំទៅម៉េចបាន? ង៉ៃសៅរ៍បានអត់ចុះ?

បងប្រុស៖ ង៉ៃសៅរ៍បានតាស។

ប្អូនស្រី៖ អូខេ អីចឹងសម្រេចង៉ៃសៅរ៍សិនហើយ។ ខ្ញុំសួរពួកម៉ាកខ្ញុំសិន បើគេទៅអត់បាន ចាំខ្ញុំប្រាប់បងតាមក្រោយ។

| | |
|---|---|
| សុភ័ក្រ / សម្ផស្ស / ពិសី | male or female / female / female Cambodian names |
| អេ៉ | spoken form of the question or negation particle ទេ |
| ថាអញ្ចេក ... | the thing is, ... |
| ង៉ៃ | spoken form of ថ្ងៃ = day |
| ថា ... អ៊ំ = ថា ... នោះ | we/you/I said ... (used to remind someone about something that was said or decided upon) |
| លើកទៅ | to change to, to postpone to |
| បានបានមកវិញ | equivalent to ទើបបានមកវិញ = [only] then I can [meet you] |
| សម្រេចថា ... | then we’re agreed to ..., then we will ..., then ... is decided |
| មើលកុំព្យូទ័រឲ្យ | to look at a computer in order to buy it; to fix a broken computer |

Copyright © 2017 www.aakanee.com – This document is provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

| | |
|---|---|
| ទាល់តែខ្ញុំសួរ ... សិន | I need to ask/check with ... first |
| បើមិននេះ | if it's ok [for you], if it's no problem [for you] |
| ម៉ង | spoken form of តែម្តង = directly |
| ង៉ៃស្អែកខ្ញុំទៅម៉េចបាន ? | rhetorical question, something like: How can I go tomorrow? |

## Cultural notes

ការណាត់ជួបឬលុបចោលការណាត់ជួបភ្លាមៗ កើតមានញឹកញាប់នៅខ្មែរ។ ពេលខ្លះក៏មានអ្នកភ្លេចការណាត់ជួបតែម្តង។ នៅខ្មែរ មនុស្សជាច្រើនប្រកបមុខរបរជាអ្នករកស៊ីដែលរវល់ធ្វើការទាំងថ្ងៃសៅរ៍ថ្ងៃអាទិត្យ ធ្វើឲ្យពួកគេមិនសូវចាំថាជាថ្ងៃអ្វីឬថ្ងៃទីប៉ុន្មាននោះទេ។

| | |
|---|---|
| លុបចោល | to cancel |
| ប្រកបមុខរបរ | to have an occupation, to have a job |
| អ្នករកស៊ី | businessman |

## Additional dialogue

ប្អូនស្រី៖ អាឡូ បង! បងឯងមកដល់នៅ?
បងប្រុស៖ អូនឯងនៅណា?
ប្អូនស្រី៖ នៅហាងកុំព្យូទ័រ។ ក្រែងយើងណាត់គ្នាមកជួយមើលកុំព្យូទ័រឲ្យពួកម៉ាកខ្ញុំអ៎?
បងប្រុស៖ អូ! ង៉ៃហ្នឹងង៉ៃសៅរ៍អ៎ា? ភ្លេចឲ្យឈឹង!
ប្អូនស្រី៖ ងាប់! ចេះភ្លេចទៅកើត។ ឥឡូវបងឯងម៉ោបានអេ៎?
បងប្រុស៖ បងប្រហែលមួយម៉ោងទៀតបានទៅដល់។ ដើរមើលលេងៗសិនទៅ។ តិចទៀតទៅដល់ហើយ។
ប្អូនស្រី៖ ម៉ោឲ្យលឿនម៉ោអីចឹង។ ពួកខ្ញុំចាំ។ បងឯងនេះ!

| | |
|---|---|
| ក្រែង ... អ៎/អេ៎? | Aren't we / Isn't it that ... ? |
| អ៎ា | spoken form of ហើយ |
| ភ្លេចឲ្យឈឹង | I've totally forgotten [about it] |
| ងាប់! | Damn! / Gosh! (exclamation expressing surprise and disappointment) |
| ចេះភ្លេចទៅកើត | How could you have forgotten! |
| បងឯងនេះ! | Oh, brother! (expressing disappointment) |

Copyright © 2017 www.aakanee.com – This document is provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.